ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ០០៩៦៤ ប្រក .

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបែងចែកចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ...១១៩៥៥៤... ចុះថ្ងៃទី...២៨... ខែ...វិច្ឆិកា... ឆ្នាំ២០១៩ ស្តីពីការប្រមូលចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្របាត់ដំបង
- យោងតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ១ .-**

អនុញ្ញាតឱ្យរដ្ឋបាលខេត្តបាត់ដំបង បែងចែកចំណូលប្រមូលបានពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង(**អគារសាលាខេត្តបាត់ដំបងចាស់**) តាមការកំណត់ដូចខាងក្រោម ÷

- ថវិកា ៥០% នៃចំណូលប្រមូលបាន សម្រាប់ទូទាត់ជូនក្រុមហ៊ុន **សយ ប៉ូរ៉ា ឌីវេឡុបម៉ិន ឯ.ក** រហូតដល់ចប់កិច្ចសន្យា ដើម្បីបង់រំលស់ថ្លៃចំណាយជួសជុល និងរៀបចំដាក់ឱ្យដំណើរការសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង។
- ថវិកា ៥០% ដែលនៅសល់ ត្រូវធ្វើការបែងចែកបន្តដូចតទៅ ÷
  + ថវិកា ២០% នៃថវិកាដែលនៅសល់ សម្រាប់បង់ចូលថវិការបស់រដ្ឋបាលខេត្តបាត់ដំបង
  + ថវិកា ៥០% នៃថវិកាដែលនៅសល់ សម្រាប់ចំណាយលើការថែទាំ ការអភិរក្ស និងការជួសជុលសារមន្ទីរ ព្រមទាំងប្រាក់ឧបត្ថម្ភជូនបុគ្គលិករដ្ឋបាលខេត្តបាត់ដំបងដែលបំពេញភារកិច្ចក្នុងសារមន្ទីរ
  + ថវិកា ២៩% នៃថវិកាដែលនៅសល់ សម្រាប់រង្វាន់លើកទឹកចិត្តជូនបុគ្គលិករដ្ឋបាលខេត្តបាត់ដំបងដទៃទៀតដែលមានការពាក់ព័ន្ធ
  + ថវិកា ១% នៃថវិកាដែលនៅសល់ សម្រាប់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង។

**ប្រការ២ .-**

ចំណូលប្រមូលបានពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ត្រូវកត់ត្រាជាចំណូលថវិការបស់រដ្ឋបាលខេត្តបាត់ដំបង ដោយមិនកត់ត្រាបញ្ចូលនូវចំណែកថវិកាដែលរដ្ឋបាលខេត្តត្រូវបំពេញកាតព្វកិច្ចទូទាត់ជូនក្រុមហ៊ុន **សយ ប៉ូរ៉ា ឌីវេឡុបម៉ិន ឯ.ក** តាមកិច្ចសន្យានោះទេ។

**ប្រការ៣ .-**

អនុញ្ញាតឱ្យរដ្ឋបាលខេត្តបាត់ដំបង បុរេប្រទានថវិកាពីចំណូលប្រមូលបាន ទៅតាមអត្រាដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ដើម្បីចាត់ចែងការចំណាយដូចខាងក្រោម ÷

- ចំណាយលើការថែទាំ ការអភិរក្ស និងការជួសជុលសារមន្ទីរ ព្រមទាំងប្រាក់ឧបត្ថម្ភជូនបុគ្គលិកដែលបំពេញភារកិច្ចក្នុងសារមន្ទីរ
- បើកផ្តល់រង្វាន់លើកទឹកចិត្តជូនបុគ្គលិករដ្ឋបាលខេត្តបាត់ដំបង
- បើកផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង។

**ប្រការ៤ .-**

រដ្ឋបាលខេត្តបាត់ដំបង ត្រូវគ្រោងឥណទានចំណាយលើការថែទាំ ការអភិរក្ស និងការជួសជុលសារមន្ទីរ, ប្រាក់ឧបត្ថម្ភជូនបុគ្គលិកដែលបំពេញភារកិច្ចក្នុងសារមន្ទីរ, រង្វាន់លើកទឹកចិត្តរបស់រដ្ឋបាលខេត្តបាត់ដំបង និងរង្វាន់លើកទឹកចិត្តរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ឥណទានចំណាយដែលបានគ្រោង ជាកម្មវត្ថុសម្រាប់ការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលប្រមូលបាន។

រាល់ប្រតិបត្តិការចំណាយខាងលើនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិការបស់រដ្ឋបាលខេត្តបាត់ដំបង ដូចកិច្ចប្រតិបត្តិការចំណាយដទៃទៀតរបស់រដ្ឋបាលខេត្តបាត់ដំបងដែរ។

**ប្រការ៥ .-**

ជារៀងរាល់ខែ រដ្ឋបាលខេត្តបាត់ដំបង ត្រូវទូទាត់ថវិកាដែលបានបុរេប្រទាន តាមនីតិវិធីដែលកំណត់ដូចខាងក្រោម ÷

**ក. ផ្នែកចំណូល**

ធ្វើសលាកប័ត្របង់ចំណូលនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងធ្វើសំណើសុំកត់ត្រាចំណូល បញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ដោយភ្ជាប់ជាមួយនូវតារាងបែងចែកចំណូលប្រមូលបាន តាមការកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ, សលាកប័ត្របង់ចំណូលដែលបានបង់ចូលថវិកាខេត្តនូវចំណែកថវិកា ២០%, របាយការណ៍ចំណាយថវិកាដែលបានបុរេប្រទាន និងរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ ដែលបានចុះក្នុងសលាកប័ត្របង់ចំណូល នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទានដោយរដ្ឋបាលខេត្តបាត់ដំបង។

**ខ. ផ្នែកចំណាយ**

រដ្ឋបាលខេត្តបាត់ដំបង ត្រូវធ្វើសំណើសុំទូទាត់ថវិកាបុរេប្រទាន និងធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកប័ត្របង់ចំណូល។

**ប្រការ៦ .-**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនបុគ្គលិកនៃរដ្ឋបាលខេត្តបាត់ដំបង ត្រូវអនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្តបាត់ដំបង ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៧ .–**

ការបែងចែកប្រាក់ចំណូលប្រមូលបានពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ត្រូវពិនិត្យ និងកែសម្រួលឡើងវិញ នៅរៀងរាល់ ៥(ប្រាំ)ឆ្នាំម្តង។

**ប្រការ៨ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .–**

អគ្គលេខាធិការ អគ្គស្នងការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ